ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**សម្តេចពិជ័យសេនា ទៀ បាញ់**

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

**សូមគោរពជូន**

**សម្តេច ឯកឧត្តម លោកជំទាវ**

**ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋមន្ត្រីប្រតិភូ រដ្ឋលេខាធិការ**

**ព្រមទាំងមន្ត្រីរាជការគ្រប់ក្រសួង-ស្ថាប័ន រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា**

ជាបឋម ខ្ញុំនិងភរិយា សូមសម្តែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ **សម្តេច ឯកឧត្តម លោកជំទាវ លោក លោកស្រី មន្ត្រីរាជការគ្រប់ក្រសួង-ស្ថាប័ន** ដែលបានផ្ញើសារលិខិតអំណរសាទរដ៏កក់ក្តៅបំផុត ក្នុងឱកាសដែលរូបខ្ញុំ បានទទួលនូវគោរមងារជា **សម្តេចពិជ័យសេនា ទៀ បាញ់** ដែលជាការប្រោសប្រទានដ៏ឧត្តុង្គឧត្តម នៃ **ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ។

ដើម្បីឲ្យសក្តិសមទៅនឹងព្រះរាជគោរមងារដ៏វិសេសវិសាលនេះ ខ្ញុំសូមសន្យាថា នឹងខិតខំបំពេញភារកិច្ចដឹកនាំវិស័យការពារជាតិ ឲ្យអស់ពីកម្លាំងកាយចិត្ត ប្រាជ្ញា ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ និងពុះពារជម្នះរាល់ឧបសគ្គ ដើម្បីបុព្វហេតុ ឧត្តមប្រយោជន៍ជាតិ និងមាតុភូមិជាទីស្នេហានៃយើង សម្រាប់ធានាឲ្យបាននូវសុខសន្តិភាព និងស្ថិរភាពនយោបាយ ដែលជាមូលដ្ឋានគ្រឹះ សម្រាប់ការអភិវឌ្ឍន៍ប្រទេសជាតិ ឲ្យកាន់តែរីកចម្រើនលើគ្រប់វិស័យ ។

ខ្ញុំសូមជូនពរ **សម្តេច ឯកឧត្តម លោកជំទាវ លោក លោកស្រី មន្ត្រីរាជការគ្រប់ក្រសួង-ស្ថាប័ន** សូមប្រកបតែពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ និងសូមសម្រេចបានជោគជ័យគ្រប់ភារកិច្ចក្នុងការបម្រើជាតិ និងមាតុភូមិ ។

សូម **សម្តេច ឯកឧត្តម លោកជំទាវ លោក លោកស្រី មន្ត្រីរាជការគ្រប់ក្រសួង-ស្ថាប័ន** ទទួលនូវការគោរព និងរាប់អានដ៏ជ្រាលជ្រៅអំពីខ្ញុំ ។

រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៧

**ទៀ បាញ់**